## ស្ថានទូតអូស្ត្រាលី

## រាជធានីភ្នំពេញ

# សេចក្តីប្រកាសព័ត៌មាន

# អូស្ត្រាលីគាំទ្រដល់ការគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់នៅកម្ពុជា

នៅថ្ងៃពុធ ទី២៧ ខែកក្កដា ឆ្នាំ២០១១ ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណៈនិងដឹកជញ្ជូន នឹងអញ្ជើញជាអធិបតីក្នុងពិធីដ៏សំខាន់មួយដើម្បីសំភោធការសំរេចបានការជួសជុលថែទាំផ្លូវជាតិលេខ៥ ប្រវែង៨៧ គីឡូម៉ែត ពីរាជធានីភ្នំពេញដល់ខេត្តកំពង់ឆ្នាំងដែលជាផ្នែកនៃគំរោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់នៅកម្ពុជា ។

ឯកឧត្តមរដ្ឋមន្ត្រី នឹងធ្វើការបើកការដ្ឋានជួលជុលផ្លូវប្រវែង៨0គីឡូម៉ែតបន្ថែមទៀត ពីខេត្តកំពង់ឆ្នាំង រហូតដល់ខេត្តពោធិសាត់ផងដែរ ។

គំរោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវ ថ្នល់ផ្តល់ការគាំទ្រដល់ក្រសួងសាធារណៈការនិងដឹកជញ្ជូនក្នុងការថែទាំផ្លូវ សរុបប្រមាណ៩៥0គីឡូម៉ែត និងសហការជាមួយរាជរដ្ឋាភិបាលក្នុងការកែលំអសមត្ថភាពគ្រប់គ្រងថែទាំផ្លូវថ្នល់ ។

គំរោងនេះត្រូវបានផ្តួចផ្តើមឡើង ក្រោមកិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលអូស្ត្រាលីតាមរយៈ ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងអង្គការអូពិចដើម្បី អភិវឌ្ឍន៍អន្តរជាតិ(OFID) ។ សមាគមអភិវឌ្ឍន៍អន្តរជាតិ(IDA) ក៏រួមចំណែកផ្តល់វិភាគទានហិរញ្ញវត្ថុដល់ គំរោងផងដែរ ។

ឯកឧត្តមរដ្ឋមន្ត្រីបានមានប្រសាសន៏ថា: «ហិរញ្ញប្បទានសហប្រតិបត្តិការដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍បាន សំរាលបន្ទុករាជរដ្ឋាភិបាលក្នុងការថែទាំផ្លូវនៅកម្ពុជា » ។

“ការថែទាំទ្រព្យសម្បត្តិផ្លូវថ្នល់មានសារៈសំខាន់ណាស់ក្នុងការរក្សាគុណភាពផ្លូវថ្នល់ដើម្បីប្រើប្រាស់អោយបាន យូរអង្វែង” បើតាមប្រសាសន៏របស់លោកស្រី Jennifer Lean នាយកស្តីទីនៃទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍ អន្តរជាតិ (AusAID) ។

ផ្លូវដែលល្អនឹងជួយកាត់បន្ថយចំណាយ និងពេលវេលាក្នុងការធ្វើដំណើរ ពិសេសចំពោះប្រជាជនដែលរស់នៅ តំបន់ដាច់ស្រយាល ។ហើយវាក៏តភ្ជាប់កសិករកម្ពុជាទៅកាន់ទីផ្សារក្នុងស្រុកនិងក្នុងតំបន់ផងដែរ ។ លោកស្រីLean បាន មានប្រសាសន៏បន្ថែមថា: «ដោយចំនួនអ្នកប្រើប្រាស់ផ្លូវមានការកើនឡើង គ្រោះថ្នាក់ចរាចរណ៏ក៏នឹងមានការកើន

ឡើងផងដែរ ។ នេះជាហានិភ័យមួយដែលទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៏អន្តរជាតិ (AusAID)បានទទួលស្គាល់ ។ ហេតុនេះហើយការគាំទ្ររបស់អូស្ត្រាលីចំពោះគំរោងនេះក៏រួមបញ្ចូលនូវយុទ្ធនាការសុវត្ថិភាពផ្លូវថ្នល់ ដែលបង្កើនការយល់ដឹងដល់ប្រជាជនកម្ពុជា អំពីសារៈសំខាន់នៃការពាក់មួកសុវត្ថិភាព និងការគោរពច្បាប់ ចរាចរណ៍ » ។

ប្រទេសអូស្ត្រាលីបានគាំទ្រការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធតាំងពីទសវត្ស១៩៩០មកម្ល៉េះ ។ បច្ចុប្បន្នអូស្ត្រាលី កំពុងវិនិយោគប្រមាណ៨៩លានដុល្លាអូស្ត្រាលីក្នុងប្រទេសកម្ពុជាលើគំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលរួមមានៈ គំរោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់ គំរោងច្រករបៀងឆ្នេរសមុទ្រទិសនិរតី គំរោងស្តារឡើងវិញផ្លូវដែកនៅកម្ពុជា និងគំរោងអគ្គិសនីជនបទ ។

**ព័ត៌មានបន្ថែមៈ**

| | |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ |
| ទីកន្លែង | ទីរួមខេត្តកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង |
| ទំនាក់ទំនងផ្នែកព័ត៌មាន | Dave Gordge លេខាទី១ ស្ថានទូតអូស្ត្រាលី ទូរស័ព្ទ ០២៣ ២១៣ ៤៧០ |